ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ....២៤៧៧៤......អពដ

L202606230597TD3545

ថ្ងៃ អង្គារ ៨ កើត ខែ បឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង

## ស្តីពី

## វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារ ជំនាន់ទី២១ លើកទី២

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនលោក លោកស្រី អ្នកនាងកញ្ញា ដែលជាសិស្ស និស្សិត អ្នកជាប់ពន្ធ បុគ្គលិកក្រុមហ៊ុន និងសាធារណជនទូទៅឱ្យបានជ្រាបថា អគ្គនាយកដ្ឋានពន្ធដារនឹងរៀបចំបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារ ជំនាន់ទី២១ លើកទី២ ដែលនឹងត្រូវចូលរៀននៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៦។

- **ទីកន្លែងសិក្សា៖** សិក្សាតាមប្រព័ន្ធអនឡាញ និងសិក្សាផ្ទាល់នៅសាលាជាតិពន្ធដារ
- **ការចុះឈ្មោះសិក្សា និងការបង់ថ្លៃសិក្សា៖** តាមរយៈប្រព័ន្ធ "គ្រប់គ្រងការសិក្សាពន្ធដារ" នៅគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh/km/e-service
- **ចាប់ផ្តើមទទួលចុះឈ្មោះចូលរៀនចាប់ពីថ្ងៃជូនដំណឹងនេះតទៅ (កន្លែងមានកំណត់)។**

សេចក្តីដូចបានជម្រាបជូនដំណឹងខាងលើ ប្រសិនបើលោក លោកស្រី អ្នកនាងកញ្ញា ដែលជាសិស្ស និស្សិត អ្នកជាប់ពន្ធ បុគ្គលិកក្រុមហ៊ុន ឬសាធារណជនទូទៅមានបំណងចូលរួមវគ្គបណ្តុះបណ្តាលនេះ សូមប្រញាប់ចុះឈ្មោះឱ្យបានទាន់ពេលវេលា។

អាសយដ្ឋានសាលាជាតិពន្ធដារ៖ អគារលេខ ៤១-៤៣ ផ្លូវលេខ ១១២ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ខាងកើតអគ្គនាយកដ្ឋានពន្ធដារ) ឬទំនាក់ទំនង Hotline ១២៧៧។

**អគ្គនាយកដ្ឋានពន្ធដារ**

ព្រះរាជាណាចក្រកម្ពុជា * អគ្គនាយកដ្ឋានពន្ធដារ * ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ស្កេនដើម្បី
ចុះឈ្មោះចូលរៀន

ស្កេនដើម្បី
សាកសួរព័ត៌មាន

**អគ្គនាយកដ្ឋានពន្ធដារ**
GENERAL DEPARTMENT OF TAXATION
**សាលាជាតិពន្ធដារ**
NATIONAL TAX SCHOOL

# វគ្គបណ្តុះបណ្តាល
## ជំនាញវិជ្ជាជីវៈពន្ធដារជំនាន់ទី២១
## លើកទី២
## ចូលរៀនថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៦

**ចុះឈ្មោះចូលរៀនចាប់ពី ថ្ងៃជូនដំណឹងនេះតទៅ**



## គោលបំណង

វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារ រៀបចំឡើង ដើម្បីផ្តល់ឱកាសដល់សិស្ស និស្សិត អ្នកជាប់ពន្ធក៏ដូចជាសាធារណជនទូទៅក្លាយខ្លួនជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលមានជំនាញឯកទេសពិតប្រាកដក្នុងការផ្តល់សេវាពាក់ព័ន្ធនឹងពន្ធដារជូនអ្នកជាប់ពន្ធប្រកបដោយគុណភាព និងវិជ្ជាជីវៈ។

**តម្លៃសិក្សា ៣៦០ ដុល្លារ**

## អត្ថប្រយោជន៍

- យល់ដឹងអំពីច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានារបស់អគ្គនាយកដ្ឋានពន្ធដារ
- សិក្ខាកាមដែលបានបំពេញគ្រប់លក្ខណ្ឌក្នុងការទទួលវិញ្ញាបនបត្រអាចស្នើសុំអាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដារ
- សិក្ខាកាមអាចស្នើសុំកាត់កងក្រេឌីតសិក្សាជាមួយគ្រឹះស្ថានឧត្តមសិក្សា ដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអគ្គនាយកដ្ឋានពន្ធដារ និងអត្ថប្រយោជន៍ផ្សេងៗទៀត។

## កម្មវិធីសិក្សា

សិក្ខាកាមត្រូវសិក្សា៖

| | |
|---|---|
| - មុខវិជ្ជាតម្រូវទី១ | មាន ៣ ក្រេឌីត |
| - មុខវិជ្ជាតម្រូវទី២ | មាន ៣ ក្រេឌីត |
| - មុខវិជ្ជាឯកទេស + មុខវិជ្ជាជ្រើសរើស | មាន ៣ ក្រេឌីត |

សរុបសិក្សាចំនួន ១៤៧ម៉ោង ស្មើនឹង ៩ ក្រេឌីត



## ឯកទេស

១. ឯកទេសពន្ធលើប្រាក់ចំណូល
២. ឯកទេសអាករលើតម្លៃបន្ថែម
៣. ឯកទេសការដាក់លិខិតប្រកាសពន្ធតាមអនឡាញ និងការប្រើប្រាស់សេវាអេឡិចត្រូនិកពន្ធដារ

**ស្កែនទីនេះ ដើម្បីទទួលបានព័ត៌មាន**

**ស្កែនទីនេះ ដើម្បីចុះឈ្មោះចូលរៀន**


**សាលាជាតិពន្ធដារ÷** អគារលេខ ៤១-៤៣ ផ្លូវលេខ ១១២ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ
Tel: (855) 23 881 910 E-mail: nts@tax.gov.kh
Hotline: 1277 ចុចលេខ 1 រួចចុចលេខ 6600 រៀងរាល់ម៉ោងធ្វើការ